**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០...សហវ.គសគ.ត.គសហ

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតក្រុមការងារសិក្សាអំពីការលើកកម្ពស់ភាពប្រកួតប្រជែង របស់អាកាសយានដ្ឋានអន្តរជាតិតេជោ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម /០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម /១១២៣/០២០ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧២៣/១៥៦៣ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើត **«ក្រុមការងារសិក្សាអំពីការលើកកម្ពស់ភាពប្រកួតប្រជែងរបស់អាកាសយានដ្ឋានអន្តរជាតិតេជោ»** សរសេរអក្សរកាត់ថា **ក.ប.តេជោ** ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ក.ស.ហ.វ.) និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (គ.ស.ហ.) | **ប្រធាន** |
| ២. ឯកឧត្តម **ស៊ឹម ធីរៈ** | អនុរដ្ឋលេខាធិការ ក.ស.ហ.វ. និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **អនុប្រធានប្រចាំការ** |
| ៣. ឯកឧត្តម **សយ សុខាន់** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល (រ.ល.អ.ស.) | **អនុប្រធាន** |
| ៤. ឯកឧត្តម **ហាច រតនៈ** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានថវិកា នៃ ក.ស.ហ.វ. | **សមាជិក** |
| ៥. ឯកឧត្តម **សុខ ពិសិដ្ឋ** | ទីប្រឹក្សាផ្ទាល់ សម្តេចមហាបវរធិបតី | **សមាជិក** |
| ៦. ឯកឧត្តម **នុត អ៊ុនវ័ណ្ណារ៉ា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | **សមាជិក** |
| ៧. ឯកឧត្តម **ឈុន មករា** | អគ្គនាយក នៃអគ្គនាយកដ្ឋានគ្រប់គ្រងឧស្សាហកម្មទេសចរណ៍ នៃក្រសួងទេសចរណ៍ | **សមាជិក** |
| ៨. លោកជំទាវ **សន សុភាវត្តី** | អគ្គនាយក នៃអគ្គនាយកដ្ឋានកស្ដុភារកម្ម នៃក្រសួងសាធារណការ និងដឹកជញ្ជូន | **សមាជិក** |
| ៩. ឯកឧត្តម **វ៉ាន់ ចន្ធី** | អគ្គនាយក នៃអគ្គនាយកដ្ឋានគោលនយោបាយដឹកជញ្ជូនតាមផ្លូវអាកាស នៃ រ.ល.អ.ស. | **សមាជិក** |
| ១០. ឯកឧត្តម **សារិន គុណ្ណាករ** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេស នៃ រ.ល.អ.ស. | **សមាជិក** |
| ១១. ឯកឧត្តម **សៅ វឌ្ឍនា** | អគ្គនាយក នៃអគ្គនាយកដ្ឋានប្រតិបត្តិការ និងសេវាកម្ម នៃ រ.ល.អ.ស. | **សមាជិក** |
| ១២. ឯកឧត្តម **ឱម ម៉ាក់ធារិទ្ធ** | អគ្គនាយក នៃអគ្គនាយកដ្ឋានភាពជាដៃគូរវាងរដ្ឋ និងឯកជន (អ.រ.ជ.) នៃ ក.ស.ហ.វ. | **សមាជិក** |
| ១៣. ឧកញ៉ា **វ៉ាន់ ឆារស៍ ជួន** | នាយកប្រតិបត្តិ អាកាសយានដ្ឋានអន្តរជាតិតេជោ | **សមាជិក** |
| ១៤. ឯកឧត្តម **គីម មិនា** | នាយកប្រតិបត្តិ នៃក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (ក.ផ.ផ.) | **សមាជិក** |
| ១៥. ឯកឧត្តម **ប៊ិន សិរីវុធ** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | **សមាជិក** |
| ១៦. លោក **ឈឹម សុចរស្មី** | អគ្គនាយករង នៃ អ.រ.ជ. នៃ ក.ស.ហ.វ. | **សមាជិក** |

| | | |
|---|---|---|
| ១៧. លោក **ប៉ែន ទិបុលសក្តិ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍គម្រោង នៃ អ.រ.ជ. នៃ ក.ស.ហ.វ. | **សមាជិក** |
| ១៨. លោក **សុខ កុសល** | អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ (អ.ព.ដ.) នៃ ក.ស.ហ.វ. | **សមាជិក** |
| ១៩. លោក **លឹម សម្បត្តិ** | អនុប្រធាននាយកដ្ឋានគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃ ក.ស.ហ.វ. | **សមាជិក** |
| ២០. លោក **សុត គីមសុន** | ប្រធានការិយាល័យគោលនយោបាយពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ នៃ ក.ស.ហ.វ. | **សមាជិក** |
| ២១. លោក **ជា អេងគីមស្រៀង** | ប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃ អ.ព.ដ. នៃ ក.ស.ហ.វ. | **សមាជិក** |
| ២២. លោក **គឹម សុតបុត្ត** | មន្ត្រីជាន់ខ្ពស់ផ្នែកសិក្សាទីផ្សារ និងទិន្នន័យ នៃ ក.ផ.ផ. | **សមាជិក** |
| ២៣. លោក **ខាន់ ឃីសាន** | ប្រធានវិស្វករ អាកាសយានដ្ឋានអន្តរជាតិតេជោ | **សមាជិក** |
| ២៤. លោកស្រី **ស៊ុនសី សិរីវរលក្ខណ៍** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ២៥. កញ្ញា **ថៃ បញ្ញាលក្ខិ** | មន្ត្រីនៃអគ្គនាយកដ្ឋានគោលនយោបាយនៃ ក.ស.ហ.វ. | **សមាជិក** |
| ២៦. កញ្ញា **ជូ សុភ័ក្រ្ត** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ២៧. កញ្ញា **ជូ សិរីវឌ្ឍិនី** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ២៨. លោកស្រី **ខូច មួយឡេង** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ២៩. លោក **ខាន់ លីហួរ** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ៣០. កញ្ញា **ភូ សុធារតន៍** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ៣១. កញ្ញា **ស៊ុនសី សិរីវរនាថ** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក** |
| ៣២. កញ្ញា **អៀង អែម៉ា វណ្ណវត្តី** | ជំនួយការស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋាន គ.ស.ហ. | **សមាជិក។** |

**ប្រការ២.-**

ក្រុមការងារនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- ដឹកនាំ និងសម្របសម្រួល ដើម្បីធ្វើការសិក្សា និងលើកអនុសាសន៍ ដោះស្រាយបញ្ហាប្រឈមនានា ពាក់ព័ន្ធនឹងកម្រៃសេវាសម្រាប់អ្នកដំណើរ និងសេវាកម្មអាកាសចរណ៍នានា នៅអាកាសយានដ្ឋានអន្តរជាតិតេជោ សំដៅកាត់បន្ថយបន្ទុកធុរកិច្ច និងបង្កើតភាពងាយស្រួលក្នុងការធ្វើធុរកិច្ច និងវិនិយោគ
- សិក្សា និងកំណត់យន្តការ និងស្នើឡើងនូវវិធានការមុតស្រួច ដែលមានលក្ខណៈអន្តរស្ថាប័ន ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់អាកាសយានដ្ឋានអន្តរជាតិតេជោ ឱ្យកាន់តែមានឧត្តមភាព និងសក្តានុពលខ្ពស់ សម្រាប់ជំរុញការលូតលាស់នៃវិស័យអាកាសចរណ៍ ទេសចរណ៍ ឡូជីស្ទីក និងវិស័យពាក់ព័ន្ធដទៃទៀត
- ពិនិត្យ តាមដាន និងវាយតម្លៃប្រសិទ្ធភាពនៃយន្តការ និងវិធានការ ដែលបានដាក់ឱ្យអនុវត្ត និងរៀបចំរបាយការណ៍វឌ្ឍនភាពការងារ ដើម្បីជូនរាជរដ្ឋាភិបាល តាមរយៈ គ.ស.ហ.; និង
- បំពេញភារកិច្ចផ្សេងទៀត តាមការណែនាំរបស់ គ.ស.ហ.។

**ប្រការ៣.-**

អនុប្រធាន និងសមាជិកនៃក្រុមការងារនេះត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារនេះ។ ក្នុងករណីប្រធានអវត្តមាន ឬ ករណីចាំបាច់ ប្រធានអាចប្រគល់សិទ្ធិជូនអនុប្រធានដឹកនាំប្រជុំជំនួសបាន។

ប្រធានក្រុមការងារនេះ មានសិទ្ធិអញ្ជើញតួអង្គសំខាន់ៗ ដូចជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន និងស្ថាប័នសិក្សាស្រាវជ្រាវ ដើម្បីចូលរួមប្រជុំ និងប្រមូលធាតុចូលតាមការចាំបាច់។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

អគ្គលេខាធិការដ្ឋាន គ.ស.ហ. និងរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តខ្លឹមសារនៃសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ ម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០២៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ